ទីស្ដីការគណៈរដ្ឋមន្ត្រី
Office of the Council of Ministers

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
Council for the Development of Cambodia

Australian Embassy
Cambodia

*ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៥*

# សេចក្ដីប្រកាសព័ត៌មានរួម

## កម្ពុជា និងអូស្ត្រាលី រៀបចំសិក្ខាសាលាជំនាញលើពិពិធកម្មសេដ្ឋកិច្ច

ថ្ងៃនេះ កម្ពុជា និងអូស្ត្រាលីបានរៀបចំសិក្ខាសាលាជាន់ខ្ពស់មួយ ស្ដីពី "មាគ៌ាឆ្ពោះទៅការបង្កើនពិពិធកម្មសេដ្ឋកិច្ចកម្ពុជា៖ បទពិសោធន៍អន្តរជាតិ" ចូលរួមដោយ លោកសាស្ត្រាចារ្យ Ricardo Hausmann នាយកស្ថាប័នស្រាវជ្រាវ Growth Lab នៃសាកលវិទ្យាល័យ Harvard ដើម្បីពិភាក្សាអំពីយុទ្ធសាស្ត្រសម្រាប់បង្កើនពិពិធកម្មសេដ្ឋកិច្ចកម្ពុជា។

ការធ្វើពិពិធកម្មផលិតផលថ្មី និងផលិតផលដែលមានលក្ខណៈកាន់តែជឿនលឿន គឺជាកត្តាចម្បងក្នុងការជំរុញកំណើនសេដ្ឋកិច្ច។ យោងតាមទស្សនទានរបស់ លោកសាស្ត្រាចារ្យ Hausmann អំពីការវិភាគលើកំណើន (*Growth Diagnostics*) សេដ្ឋកិច្ចដែលមានពិពិធភាព (*Economic Complexity* ) និងលំហផលិតផល (*Product Space*) បានលើកឡើងថាជារឿយៗ ការសម្រេចបានកំណើនសេដ្ឋកិច្ចអាស្រ័យលើផលិតផលចម្រុះទំនើបដែលប្រទេសមួយអាចផលិត និងនាំចេញបាន។ អ្នកចូលរួមសិក្ខាសាលា បានពិភាក្សាអំពីលទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រសមស្របនៅក្នុងបរិបទសេដ្ឋកិច្ចកម្ពុជានាពេលបច្ចុប្បន្ន និងកំណត់កាលានុវត្តភាពដ៏មានប្រសិទ្ធភាពបំផុតសម្រាប់ការធ្វើពិពិធកម្ម និងកំណើន។

សិក្ខាសាលានេះប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ ឯកឧត្ដម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី និងអនុប្រធានទី១ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឯកឧត្ដម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ ទទួលបន្ទុក ទីស្ដីការគណៈរដ្ឋមន្ត្រី និងឯកឧត្ដម ដេរីក យីប ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំព្រះរាជាណាចក្រកម្ពុជា។ សិក្ខាសាលានេះផងដែរ មានការចូលរួមពីមន្ត្រីជាន់ខ្ពស់ខាងទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា។

ឯកឧត្ដម ស៊ុន ចាន់ថុល បានមានប្រសាសន៍ថា៖ *"រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងអនុវត្តផែនការគោលដៅដើម្បីទាក់ទាញការវិនិយោគផ្ទាល់ពីបរទេសដែលមានគុណភាពខ្ពស់ ក៏ដូចជាពង្រីកសមត្ថភាពឧស្សាហកម្មក្នុងប្រទេស និងបង្កើនប្រសិទ្ធភាពនៃសមាហរណកម្មខ្សែច្រវាក់តម្លៃសកល (Global Value Chain)។ រាជរដ្ឋាភិបាលមានការសម្រេចចិត្តខ្ពស់ក្នុងការបង្កើតបរិការណ៍សេដ្ឋកិច្ចមួយ ដែលជំរុញភាពច្នៃប្រឌិត គាំទ្រផ្នែកសហគ្រិនភាព និងជំរុញភាពធន់នៃសេដ្ឋកិច្ចរយៈពេលវែង"*។

ឯកឧត្ដម វង្សី វិស្សុត បានមានប្រសាសន៍ថា៖ *សិក្ខាសាលាជាន់ខ្ពស់នេះ ផ្ដល់ឱកាសដ៏កម្រមួយសម្រាប់អ្នករៀបចំគោលនយោបាយ អ្នកជំនាញអន្តរជាតិ និងអ្នកអនុវត្ត ដៃគូអភិវឌ្ឍ អ្នកស្រាវជ្រាវ និងភាគីពាក់ព័ន្ធនានា ដើម្បីពិភាក្សាស៊ីជម្រៅលើសំណួរសំខាន់ៗដែលដឹកនាំអនាគតនៃការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជា៖ សំណួរទីមួយ តើកម្ពុជាអាចចាប់យកសក្ដានុពល និងឱកាសរបស់ខ្លួនដើម្បីរក្សាកំណើនសេដ្ឋកិច្ចដោយរបៀបណា? សំណួរទីពីរ តើយើងដោះស្រាយបញ្ហាសេដ្ឋកិច្ចសង្គម ឧបសគ្គរាំងស្ទះចម្បងៗ ដើម្បីធ្វើពិពិធកម្មមូលដ្ឋានកំណើនរបស់យើង និងពង្រឹងការប្រកួតប្រជែងរបស់យើង ដើម្បីធានាឱ្យមានកំណើនប្រកបដោយបរិយាបន្ន និរន្តរភាព និងភាពធន់ដោយរបៀបណា? ហើយសំខាន់បំផុត តើយើងនឹងឈានទៅទីណាបន្ទាប់ពីនេះ?*

ឯកឧត្តម ដេរីក យីប លើកឡើងថា៖ "*អូស្ត្រាលីមានសេចក្តីរីករាយដែលបានសហការជាមួយកម្ពុជា ក្នុងការរៀបចំយុទ្ធសាស្ត្រកំណើនថ្មីមួយ សម្រាប់កម្ពុជាក្រោយពេលចាកចេញពីប្រទេសដែលមានការអភិវឌ្ឍតិចតួច។ សិក្ខាសាលានេះ គឺជាផ្នែកមួយដ៏សំខាន់នៃកិច្ចសហការរបស់យើងជាមួយក្រសួងពាក់ព័ន្ធរបស់កម្ពុជា ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍអនាគតជាចម្បងរបស់កម្ពុជា*"។

ឯកឧត្តមបានបន្ថែមទៀតថា "*អូស្ត្រាលីប្តេជ្ញាគាំទ្រកម្ពុជា ក្នុងការសម្រេចបាននូវកំណើនប្រកបដោយភាពធន់ បរិយាបន្ន និង និរន្តរភាព*"
។

សិក្ខាសាលាជាន់ខ្ពស់នេះ រៀបចំឡើងដោយ កម្មវិធីភាពជាដៃគូ កម្ពុជា អូស្ត្រាលី សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់ (CAPRED)។ កម្មវិធីនេះ មានការចូលរួមពីសំណាក់ លោកសាស្ត្រាចារ្យ Hausmann បានបញ្ជាក់ពីការប្តេជ្ញារបស់អូស្ត្រាលីដើម្បីបង្កើនកិច្ចសន្ទនាជាយុទ្ធសាស្ត្រ និងគាំទ្រកម្ពុជាឲ្យសម្រេចបាននូវកំណើន និងការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព បរិយាបន្ន និងភាពធន់។

## ប្រវត្តិរូប

**លោកសាស្ត្រាចារ្យ Ricardo Hausmann៖** លោក Ricardo Hausmann គឺជាស្ថាបនិក និងជានាយកស្ថាប័នស្រាវជ្រាវ Growth Lab នៃសាកលវិទ្យាល័យ Harvard និងជាសាស្ត្រាចារ្យ Rafik Hariri បង្រៀនលើការអនុវត្តសេដ្ឋកិច្ចនយោបាយអន្តរជាតិនៅសាកលវិទ្យាល័យ Harvard Kennedy ។ លោកសាស្ត្រាចារ្យជាអ្នកផ្តួចផ្តើមបង្កើតវិធីសាស្ត្រដើម្បីធ្វើការវិនិច្ឆ័យលើកំណើនសេដ្ឋ-កិច្ច (Growth Diagnostic) និងសេដ្ឋកិច្ចដែលមានពិពិធភាព (*Economic Complexity* ) រួមទាំងយុទ្ធសាស្ត្រសេដ្ឋកិច្ចដទៃទៀត ដូចជា Dark Matter, Original Sin, និង Self-discovery។

ចាប់តាំងពីបើកដំណើរការ Growth Lab ក្នុងឆ្នាំ ២០០៦ លោក Hausmann បានដឹកនាំសកម្មភាពស្រាវជ្រាវ ជាង៥០ គម្រោង ក្នុងប្រទេសជិត ៣០ នៅទូទាំងពិភពលោក រួមមានសហរដ្ឋអាមេរិកផងដែរ។ ការស្រាវជ្រាវទាំងនេះផ្តោតលើគោលនយោបាយអភិវឌ្ឍន៍ យុទ្ធសាស្ត្រកំណើន និងរបៀបវារៈពិពិធកម្មនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់រាជធានី។ មុនពេលចូលបម្រើការនៅសកលវិទ្យាល័យ Harvard លោកគឺជានាយកផ្នែកសេដ្ឋកិច្ច នៃធនាគារអភិវឌ្ឍអន្តរ-អាមេរិក នាយកនៃគណកម្មាការអភិវឌ្ឍធនាគារពិភពលោក និងស្ថាប័នមីក្រូហិរញ្ញវត្ថុ សមាជិកនៃ ក្រុមប្រឹក្សាភិបាលរបស់ធនាគារកណ្តាល នៃប្រទេសប្រទេសវ៉េណេស៊ុយអេឡា និងជារដ្ឋមន្ត្រីក្រសួងផែនការប្រទេសវ៉េណេស៊ុយអេឡា ពីឆ្នាំ ១៩៩២-១៩៩៣។

**កម្មវិធីភាពជាដៃគូ កម្ពុជា អូស្ត្រាលី សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់ (CAPRED)** គាំទ្រកម្ពុជាឱ្យសម្រេចបាននូវកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់ បរិយាបន្ន និងនិរន្តរភាព។ ដើម្បីសម្រេចបាននូវគោលដៅនេះ CAPRED សហការជាមួយ វិស័យឯកជន និងស្ថាប័នរាជរដ្ឋាភិបាលដែលមាន 'សមាសភាព' ចំនួនបី រួមមាន៖ ការអភិវឌ្ឍវិស័យកសិកម្ម ពាណិជ្ជកម្ម ការវិនិយោគ និងការអភិវឌ្ឍសហគ្រាស និងសេវាកម្មហេដ្ឋារចនាសម្ព័ន្ធ។ គោលដៅរបស់ CAPRED ចែកចេញជា ២ដំណាក់កាល៖ (១) ឆ្នាំ២០៣១៖ គាំទ្រដៃគូគោលដៅក្រសួង-ស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ បង្កើត និងអនុវត្តគោលនយោបាយ ដែលជំរុញដល់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព កំណើនភាពធន់ និងបរិយាបន្ន នៅក្នុងសកម្មភាពរបស់ CAPRED។ (២) ឆ្នាំ២០៣១៖ គាំទ្រដៃគូគោលដៅវិស័យឯកជន បង្កើត និងអនុវត្តគំនិតផ្តួចផ្តើមពាណិជ្ជកម្ម និងការវិនិយោគប្រកបដោយនិរន្តរភាព ភាពធន់ និងបរិយាបន្ននៅក្នុងសកម្មភាពរបស់ CAPRED។ ប្រធានបទអន្តរវិស័យសំខាន់ៗមួយចំនួន រួមមាន៖ សមភាពយេនឌ័រ ពិការ

ភាព បរិយាបន្នសង្គម (GEDSI) ភាពធន់នឹងអាកាសធាតុ និងការគាំទ្រគោលនយោបាយ។ វិធីសាស្ត្ររបស់កម្មវិធីទាំងនេះអាចធានាបានដល់ការចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព ដោយដោះស្រាយដោយផ្ទាល់នូវឧបសគ្គក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជា។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**

- ស្ថានទូតអូស្ត្រាលីប្រចាំព្រះរាជាណាចក្រកម្ពុជា៖ Media.Cambodia@dfat.gov.au